# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

## នាមនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ភ្នំពេញ

សំណុំព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ : ៣៤៣
ចុះថ្ងៃទី ២១_០៣_២០០៧
សាលដីកា
លេខ : ៧៤ "ខ"
ចុះថ្ងៃទី ២៣_០៧_២០១០

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ២៣-០៧-២០១០ ដោយមានសមាសភាពដូចខាងក្រោម:

**ក្រុមប្រឹក្សាជំនុំជម្រះ**

- លោក [redacted] ជាប្រធានក្រុមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោកជំទាវ [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជី**

កញ្ញា [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ: ៣៤៣ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៧ ដែលមាន:

១- **ជនជាប់ចោទឈ្មោះ** [redacted] **សំបូរ** ភេទប្រុស អាយុ ២៥ឆ្នាំ ជាតិខ្មែរ មុខរបរមិនពិតប្រាកដ កើតនៅភូមិរលួស ឃុំប្រធាតុ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ទីលំនៅបច្ចុប្បន្ន [redacted] ខណ្ឌដង្កោ ក្រុងភ្នំពេញ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុនគ្មាន។

២- **ជនជាប់ចោទឈ្មោះ** [redacted] **ចាន់អេង** ភេទប្រុស អាយុ ២៧ឆ្នាំ កើតនៅភូមិកោះគ ស្រុកឆ្លូង ខេត្តក្រចេះ ទីលំនៅបច្ចុប្បន្ន [redacted] ខណ្ឌដង្កោ ក្រុងភ្នំពេញ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] នៅលីវ ទោសពីមុនគ្មាន។

៣- **ជនជាប់ចោទឈ្មោះ** [redacted] **ផល្លី** ភេទប្រុស អាយុ ២៦ឆ្នាំ កើតនៅភូមិព្រៃកលីវ ឃុំរការអារ ស្រុកកងមាស ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្ន [redacted] ខណ្ឌដង្កោ ក្រុងភ្នំពេញ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] (លែងលះ) មានកូន ០១នាក់ ទោសពីមុនគ្មាន។

៤- ជនជាប់ចោទឈ្មោះ [redacted] **សារី** ភេទប្រុស អាយុ ២៧ឆ្នាំ កើតនៅភូមិជីបា ឃុំជីបា ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្នភូមិ[redacted]ខេត្តកំពង់ចាម ឪពុកមិនស្គាល់ឈ្មោះ (ស) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូន ០១នាក់ ទោសពីមុនគ្មាន។

មានលោក [redacted] ចន្ថា មេធាវីការពារជនជាប់ចោទ។

**ត្រូវជាប់ចោទពីបទៈ** ប្លន់ និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅផ្លូវលេខ ១២៨ សង្កាត់មិត្តភាព ខណ្ឌ៧មករា ក្រុងភ្នំពេញ កាលពីថ្ងៃទី ០៥ ខែវិច្ឆិកា ឆ្នាំ២០០៥ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និងមាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធជាតិផ្ទុះ និងគ្រាប់រំសេវ។

- **ជនរងគ្រោះឈ្មោះ** [redacted]**សុខហ៉ង** ភេទស្រី អាយុ ២២ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃផ្ទះលេខ ២៥៣E0 ផ្លូវ ១២៨ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ។

- តាមពាក្យបណ្តឹងឧទ្ធរណ៍លេខ ៥១៤ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់ជនជាប់ចោទឈ្មោះ [redacted] **ចាន់អេង** និងជនជាប់ចោទឈ្មោះ [redacted] **សារី** ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ១៣៩ "ដ" ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៦ របស់សាលាដំបូងរាជធានីភ្នំពេញ គ្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

- តាមពាក្យបណ្តឹងឧទ្ធរណ៍លេខ ៥២០ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់ឈ្មោះ [redacted] **សៅយុទ្ធ** ជាឪពុកជនជាប់ចោទឈ្មោះ [redacted]**ផល្លី** ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ១៣៩ "ដ" ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៦ របស់សាលាដំបូងរាជធានីភ្នំពេញ គ្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

## ដំណើររឿងមានដូចតទៅៈ

នៅថ្ងៃទី ០៥ ខែវិច្ឆិកា ឆ្នាំ២០០៥ ជនរងគ្រោះឈ្មោះ [redacted] **សុខហ៉ង** បានជិះម៉ូតូត្រឡប់ពីទិញផ្លែឈើនៅផ្សារអូរឬស្សី ពេលត្រឡប់ដល់មុខផ្ទះ មានជនល្មើសបួននាក់ បានជិះម៉ូតូ ពីរគ្រឿង មកឈប់ជិត ហើយដកកាំភ្លើងខ្លីភ្ជង់ជនរងគ្រោះ ហើយម្នាក់ទៀតបានស្ទុះមកដណ្តើមយកម៉ូតូ ហើយបើកចេញទៅ។

**បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ១៣៩ "ដ" ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៦ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលបានសម្រេចសេចក្តីដូចខាងក្រោមៈ**

១- ផ្តន្ទាទោសជនជាប់ចោទឈ្មោះ :

ក-[redacted]**សំបូរ** ភេទប្រុស អាយុ ២៧ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០៥ ឆ្នាំ (ប្រាំឆ្នាំ) គិតបន្តពីសាលក្រមលេខ ១៣៨ "ដ" ចុះថ្ងៃទី ១៣-០៩-២០០៦។

ខ- [redacted] ចាន់អេង ភេទប្រុស អាយុ ២៧ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០៥ ឆ្នាំ (ប្រាំឆ្នាំ) គិតបន្តពីសាលក្រមលេខ ១៣៨ "ដ" ចុះថ្ងៃទី ១៣-០៩-២០០៦។

គ- [redacted] ផល្លី ភេទប្រុស អាយុ ២៥ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០៥ ឆ្នាំ (ប្រាំឆ្នាំ) គិតបន្តពីសាលក្រមលេខ ១៣៨ "ដ" ចុះថ្ងៃទី ១៣-០៩-២០០៦។

ឃ- [redacted] សារី ភេទប្រុស អាយុ ២៧ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណេត់រយៈពេល ០៥ ឆ្នាំ (ប្រាំឆ្នាំ) គិតបន្តពីសាលក្រមលេខ ១៣៨ "ដ" ចុះថ្ងៃទី ១៣-០៩-២០០៦។

ពីបទ ប្លន់ និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅមុខផ្ទះលេខ ២៩៣ ផ្លូវលេខ ១២៨ សង្កាត់មិត្តភាព ខណ្ឌ៧មករា ក្រុងភ្នំពេញ កាលពីថ្ងៃទី ០៥ ខែវិច្ឆិកា ឆ្នាំ២០០៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និងមាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធជាតិផ្ទុះ និងគ្រាប់រំសេវ។

២- បង្គាប់ឱ្យឈ្មោះ [redacted] សំបូរ . [redacted] ចាន់អេង . [redacted] ផល្លី . [redacted] សារី សងសំណងការខូចខាត និងជម្ងឺចិត្តចំនួន ១២០០$ (មួយពាន់ពីររយដុល្លារអាមេរិក) ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុខហ៊ង ចាប់ពីថ្ងៃសាលក្រមចូលជាស្ថាពរ ការទាមទារលើសពីនេះត្រូវបដិសេធចោល។ ករណីគ្មានប្រាក់សងត្រូវដាក់គុកបង្ខំដល់រូបកាយតាមមាត្រា ៧-១០ នៃច្បាប់ស្តីពីការដាក់គុកបង្ខំដល់រូបកាយក្នុងរឿងព្រហ្មទណ្ឌ។

៣- សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ [redacted] សំបូរ . [redacted] ចាន់អេង . [redacted] ផល្លី . [redacted] សារី កំបាំងមុខដើមបណ្តឹង ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

- បានឃើញ ពាក្យបណ្តឹងឧទ្ធរណ៍លេខ ៥១៤ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់ជនជាប់ចោទឈ្មោះ [redacted] ចាន់អេង និងជនជាប់ចោទឈ្មោះ [redacted] សារី ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ១៣៩ "ដ" ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៦ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

- បានឃើញ ពាក្យបណ្តឹងឧទ្ធរណ៍លេខ ៥២០ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់ឈ្មោះ [redacted] សៅយុទ្ធ ជាឪពុកជនជាប់ចោទឈ្មោះ [redacted] ផល្លី ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ១៣៩ "ដ" ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៦ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍។

- បានឃើញរបាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍។

**នាពេលសវនាការ**

ប្រធានក្រុមប្រឹក្សាសង្ខេបអង្គហេតុរឿង

ប្រធានក្រុមប្រឹក្សាអានចម្លើយជនជាប់ចោទឈ្មោះ [redacted]សារី បានឆ្លើយនៅសាលាដំបូងរាជធានីភ្នំពេញ ។

ប្រធានក្រុមប្រឹក្សាអានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុខហ័ង បានឆ្លើយនៅសាលាដំបូងរាជធានីភ្នំពេញ ។

ជនជាប់ចោទឈ្មោះ [redacted] ចាន់អេង ឆ្លើយថា: ខ្លួនបានប្រព្រឹត្តដូចអង្គហេតុដែលតុលាការបានលើកឡើងមែន ។ តែកាំភ្លើងមិនមែនរបស់ខ្លួនទេ គឺរបស់ឈ្មោះ [redacted]សារី ។ សំណូមពរ សូមតុលាការមេត្តាបន្ធូរបន្ថយទោសឱ្យខ្លួនផង ។

ជនជាប់ចោទឈ្មោះ [redacted] ផល្លី ឆ្លើយថា: កាលពីថ្ងៃកើតហេតុខ្លួនពិតជាបានប្លន់ម៉ូតូគេមែន ដោយពេលប្លន់នោះ ឈ្មោះ [redacted]សារី ជាអ្នកដកកាំភ្លើងគម្រាមជនរងគ្រោះឱ្យចេញពីម៉ូតូ ហើយខ្លួនជាអ្នកទៅដកសោរម៉ូតូពីជនរងគ្រោះ ។ សំណូមពរ សូមតុលាការមេត្តាបន្ធូរបន្ថយទោសឱ្យខ្លួនផង ។

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

តំណាងមហាអយ្យការសាលាឧទ្ធរណ៍សូមសន្និដ្ឋាន:

១- មិនទទួលជំនុំជម្រះបណ្តឹងឧទ្ធរណ៍របស់ឈ្មោះ [redacted]សៅយុទ្ធ ធ្វើឡើងដោយខុសនឹងទម្រង់ច្បាប់ យោងតាមមាត្រា ៣៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌថ្មី ។

២- ទទួលបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទឈ្មោះ [redacted]ចាន់អេង និងឈ្មោះ [redacted] សារី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្អែកគតិច្បាប់ ។

៣- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៣៩ "ដ" ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៦ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល ។

## សេចក្តីសន្និដ្ឋានរបស់មេធាវី

ក្រោយពីបានស្តាប់ការសួរដេញដោល និងសេចក្តីសន្និដ្ឋានរបស់លោកព្រះរាជអាជ្ញា ឃើញថា កូនក្តីខ្លួនបានឆ្លើយសារភាពទទួលស្គាល់នូវការប្រព្រឹត្តរបស់ខ្លួន ។ ដូច្នេះ សូមប្រធានក្រុមប្រឹក្សាបន្ធូរបន្ថយទោសឱ្យកូនក្តីខ្លួនផង ។

- ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
- ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីជនជាប់ចោទ
- ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់ ។

## សាលាឧទ្ធរណ៍ភ្នំពេញ

## យល់ឃើញថា:

១- បណ្តឹងឧទ្ធរណ៍លេខ ៥១៤ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់ជនជាប់ចោទឈ្មោះ [redacted] **ចាន់អេង** និងឈ្មោះ [redacted] **សារី** ធ្វើឡើងនៅក្នុងកំណត់ច្បាប់។

- បណ្តឹងឧទ្ធរណ៍លេខ ៥២០ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់ឈ្មោះ [redacted] **សៅយុទ្ធ** ជាឪពុករបស់ជនជាប់ចោទឈ្មោះ [redacted] **ផល្លី** ធ្វើឡើងផ្ទុយនឹងទម្រង់ច្បាប់ គឺផ្ទុយនឹងមាត្រា ១៦២ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ។

២- ជនជាប់ចោទបានឆ្លើយសារភាពថា កាលពីថ្ងៃទី ០៥ ខែវិច្ឆិកា ឆ្នាំ២០០៥ បក្សពួកខ្លួនមាន ៤នាក់ គឺ ឈ្មោះ [redacted] **សំបូរ** . [redacted] **ចាន់អេង** [redacted] **ផល្លី** . [redacted] **សារី** បានជិះម៉ូតូ C១២៥ ពីរគ្រឿង ដើរធ្វើសកម្មភាពប្លន់ ដល់រង្វង់មូលនាងគង្ហីងបានឃើញនារីពីរនាក់ជិះម៉ូតូ C១២៥ ក៏ជិះតាម ដល់ផ្លូវកម្ពុជាក្រោម មុំខាងលិចសណ្ឋាគារបារីស ម៉ូតូជនរងគ្រោះឈប់ ពួកខ្លួនក៏បើកម៉ូតូឈប់ក្បែរជនរងគ្រោះ ភ្លាមនោះឈ្មោះ [redacted] **សារី** ដកកាំភ្លើង K៥៤ ភ្ជង់ជនរងគ្រោះ [redacted] **ផល្លី** យកម៉ូតូ [redacted] **សំបូរ** ដណ្តើមសោរពីជនរងគ្រោះ រួចគេចខ្លួន ហើយ [redacted] **ចាន់អេង** និង [redacted] **ផល្លី** យកម៉ូតូនោះទៅលក់ឱ្យឈ្មោះ មុំ បាន ៧៥០ ដុល្លារអាមេរិក។

៣- មានពិរុទ្ធលើជនជាប់ចោទ ពីបទ ប្លន់ និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅមុខផ្ទះលេខ ២៥៣ ផ្លូវលេខ ១២៨ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៥ ខែវិច្ឆិកា ឆ្នាំ២០០៥ បទល្មើសមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និងមាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធជាតិផ្ទុះ និងគ្រាប់រំសេវ។

៤- សាលក្រមព្រហ្មទណ្ឌលេខ ១៣៩ "ដ" ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៦ របស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចត្រឹមត្រូវតាមច្បាប់ គួរតម្កល់ទុកជាបានការ តែគួរលុបវិធានអនុវត្ត។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១- ក-ទទួលបណ្តឹងឧទ្ធរណ៍លេខ ៥១៤ ចុះថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់ជនជាប់ចោទឈ្មោះ [redacted] **ចាន់អេង** និងឈ្មោះ [redacted] **សារី** ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

ខ- មិនទទួលជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍លេខ ៥២០ ចុះថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់ឈ្មោះ [redacted] **សៅយុទ្ធ** ដោយខុសទម្រង់ច្បាប់ គឺផ្ទុយនឹងមាត្រា ១៦២ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៣៩ "ដ" ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៦ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការពេញទាំងមូល តែត្រូវលុបវិធានអនុវត្ត ។

៣- បង្គាប់ឱ្យបន្តការឃុំខ្លួនជនជាប់ចោទ ។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០១០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **ចាន់អេង** និងមេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] **សារី** និងដើមបណ្ដឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈ នៅថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០១០ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] **សារី** និងដើមបណ្ដឹងរដ្ឋប្បវេណី ចំពោះមុខមេធាវីការពារជនជាប់ចោទ និងជនជាប់ចោទឈ្មោះ [redacted] **ចាន់អេង** ។

បើកផ្លូវតវ៉ាតាមកំណត់ច្បាប់ ។

**សេចក្ដីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះ ឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា: | ហត្ថលេខា: | ហត្ថលេខា: |
| [redacted] | [redacted], [redacted] | [redacted] |

---

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី 18 ខែ 02 ឆ្នាំ២០១៤

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

[redacted]

ក្រឡាបញ្ជី

[redacted]